ប្រវត្តិសិក្សា និងការងារ

អ៊ិន សុផល្លែត

- ✓ ជំនួយការ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- ✓ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន
- ✓ ប្រធានកិត្តិយស សាលាអន្តរជាតិ ZAMAN
- ✓ សហស្ថាបនិក និងជាប្រធានកិត្តិយសសាជីវកម្ម PARAGON
- ✓ អតីតប្រធានសមាគមប្រទេសអ្នកផលិតកៅស៊ូធម្មជាតិ
- ✓ អតីតអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ✓ អតីតអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន
- ✓ អតីតនាយកគ្រប់គ្រងក្រុមហ៊ុនសាងសង់កម្ពុជា
- ✓ អតីតនាយកប្រតិបត្តិក្រុមហ៊ុន UNIVERSAL ENTERPRISE
- ✓ អតីតវិស្វករស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្រុមហ៊ុន BETTIS CANADA LTD.
- ✓ អតីតប្រតិបត្តិការវិទ្យុហ្វ្រេកង់កម្រិតខ្ពស់ UNHCR ប្រទេសថៃ
- ✓ អតីតជំនួយការគ្រូពេទ្យ MEDICINES SANS FRONTIERS
- ✓ អតីតនិស្សិតសាលា KHMER TRADITIONAL MEDICINE
- ✓ អតីតនិស្សិតវិស្វកសកលវិទ្យាល័យ CALGARY ប្រទេសកាណាដា
- ✓ អតីតសិស្សសាលា VICTORIA COMPOSITE HIGH SCHOOL
- ✓ អតីតសិស្សវិទ្យាល័យទូលទំពូង
- ✓ អតីតសិស្សសាលាវត្តកោះ
- ✓ អតីតសិស្សសាលាចតុមុខ។

សៀវភៅបែតង
កម្រងឯកសារកសិកម្ម
ភាគ ១

កម្រងឯកសារកសិកម្មរបស់ឯកឧត្តម អ៊ិង សុផល្លែត | រៀបរៀង និងចងក្រងដោយ លោក អ៊ុំ ម៉ាឡា និងកញ្ញា ប៊ិន វ៉ាន់ឌ

សៀវភៅបែតង
កម្រងឯកសារកសិកម្ម

សម្រាប់កសិករកម្ពុជា

ភាគ ១

កថាមុខ

ខ្ញុំបាទសូមថ្លែងអំណរគុណជាអនេក ដល់បងប្អូនទាំងអស់ ដែលបានផ្តល់អត្ថបទ និងរូបភាពសម្រាប់ការស្រាវជ្រាវរបស់ខ្ញុំបាទ រួមទាំងជួយកែសម្រួលអត្ថបទ និងអក្ខរាវិរុទ្ធ ហើយក៏សូមអរគុណផងដែរ ដល់ក្រុមការងារចងក្រងឯកសារ ពិសេសលោក អ៊ុំ ម៉ាឡា និងកញ្ញា ប៊ិន វ៉ាន់ឌី ដែលបានប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ចងក្រងកម្រងកំណត់ត្រាឯកសារកសិកម្ម ឱសថបុរាណធម្មជាតិ និងវាក្យសព្ទអក្សរសាស្ត្រខ្មែររបស់ខ្ញុំបាទ។

កម្រងកំណត់ត្រាឯកសារកសិកម្មនេះ គឺដើម្បីផ្តល់ជូនប្រជាកសិករកម្ពុជា ដោយមិនគិតថ្លៃ ដើម្បីជាមូលដ្ឋានយកទៅសិក្សា ស្រាវជ្រាវ ដាំដុះសាកល្បង មុនធ្វើការដាំដុះជាលក្ខណៈពាណិជ្ជកម្ម ទាំងស្ថានភាពភូមិសាស្ត្រ ស្ថានភាពអាកាសធាតុ និងស្ថានភាពដី ។ល។ គឺមានលក្ខណៈខុសប្លែកគ្នា ពីមួយកន្លែងទៅមួយកន្លែង។ ក្នុងស្ថានភាពនេះ ខ្ញុំបាទសូមប្រជាកសិករទាំងអស់ មេត្តាយកចិត្តទុកដាក់តាមដាន ធ្វើការកត់ត្រាទុក និងបំពេញបន្ថែមជាយថាហេតុ លើការស្រាវជ្រាវរបស់ខ្ញុំបាទ នេះ ធ្វើយ៉ាងណា ដើម្បីឱ្យយើងមានសៀវភៅកម្រងឯកសារកសិកម្មមួយ ដែលមានភាពជាក់ស្តែង និយម ដើម្បីរក្សាទុកសម្រាប់ប្រើប្រាស់នាពេលបច្ចុប្បន្ននេះផង និងចែកជូនដល់ប្រជាកសិករជំនាន់ក្រោយរបស់យើងផង។

តាងនាមឱ្យក្រុមការងារចងក្រងឯកសារ ខ្ញុំបាទសូមគោរពជូនពរ ដល់ប្រជាកសិករទាំងអស់ ទទួលបាននូវភាពជោគជ័យ ក្នុងការផលិតស្បៀង ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ខ្លួនផង ដើម្បីធានាសន្តិសុខស្បៀងសម្រាប់កម្ពុជាយើងផង ព្រមទាំងចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិផង។

ដោយសេចក្តីគោរព និងស្រលាញ់

អំពីខ្ញុំបាទ

អ៊ាង សុជល្លែត

មាតិកា

		ទំព័រ
០១.	បច្ចេកទេសដាំក្តាត	០១
០២.	បច្ចេកទេសដាំក្រូចឆ្មារក្នុងលូស៊ីម៉ង់ត៍	០៣
០៣.	បច្ចេកទេសធ្វើឱ្យក្រូចឆ្មារឆាប់ចេញផ្កា និងផ្លែបានច្រើន	០៦
០៤.	បច្ចេកទេសដាំក្រូចឆ្មារដោយប្រើស្លឹក	០៩
០៥.	បច្ចេកទេសដាំក្រូចឆ្មារ តាមវិធីបង្កាត់ពូជខ្មែរ-ជប៉ុន	១២
០៦.	បច្ចេកទេសដាំខ្លាយ	១៥
០៧.	បច្ចេកទេសដាំខ្ទីក្នុងបាវ	១៨
០៨.	បច្ចេកទេសដាំខ្ទឹមបារាំងក្នុងដបប្លាស្ទិច	២១
០៩.	បច្ចេកទេសដាំខ្ទឹមស	២៣
១០.	បច្ចេកទេសថ្មែដាំចេកគល់ឡើងលើ	២៦
១១.	បច្ចេកទេសដាំឆៃថាវ	២៨
១២.	បច្ចេកទេសដាំឆៃថាវឱ្យមានរសជាតិផ្អែមជាងធម្មតា	៣៣
១៣.	បច្ចេកទេសដាំជីវ៉ាន់ស៊ុយ	៣៧
១៤.	បច្ចេកទេសដាំជីអង្កាមក្នុងកញ្រ្ជែង	៤០
១៥.	បច្ចេកទេសដាំដំឡូងជ្វា	៤៣
១៦.	បច្ចេកទេសដាំដំឡូងបារាំង	៤៦
១៧.	បច្ចេកទេសដាំដំឡូងមី	៤៩

មាតិកា

		ទំព័រ
១៨.	បច្ចេកទេសដាំត្រកួន	៥៦
១៩.	បច្ចេកទេសដាំត្រកួនដោយមិនប្រើប្រាស់ដី	៥៩
២០.	បច្ចេកទេសដាំត្រប់ក្នុងផើង	៦៣
២១.	បច្ចេកទេសដាំត្រប់វែង	៦៦
២២.	បច្ចេកទេសដាំត្រប់ស្រួយ	៦៩
២៣.	បច្ចេកទេសដាំត្រសក់ចំណារ	៧៧
២៤.	បច្ចេកទេសដាំត្រសក់ផ្អែម	៨៩
២៥.	បច្ចេកទេសដាំត្រឡាច	៩៤

សៀវភៅបែតងនេះ សម្រាប់ចែកជូនប្រជាកសិករដោយឥតគិតថ្លៃ និងមិនអនុញ្ញាតឱ្យធ្វើអាជីវកម្មជាដាច់ខាត។

បងប្អូនអាចទាញយកសៀវភៅបែតងនេះដោយឥតគិតថ្លៃ និងតាមដានព័ត៌មានអំពីអក្សរសាស្ត្រខ្មែរ បរិស្ថាន កសិកម្ម និងសុខភាព តាមរយៈ៖

ខ្ញុំបាទបានបង្កើតហ្វេកប៊ុកផេច
ផ្សារកសិកម្មយើង-Our Agricultural Market
ដើម្បីលើកស្ទួយ កសិផលកម្ពុជា ជួយរកទីផ្សារជូនកសិករ និងជួយកសិករកម្ពុជា។ បើបងប្អូនកសិករមានផលិតផលចង់លក់ សូមទាក់ទងមកផេចយើងខ្ញុំ យើងខ្ញុំនឹងជួយរកទីផ្សារជូន។
www.facebook.com/OurAgriculturalMarket

ទូរសព្ទ៖ 087 70 65 65

រក្សាសិទ្ធិគ្រប់យ៉ាងដោយ អ៊ាង សុផល្លែត
បោះពុម្ពផ្សាយលើកទី១ ភាគ១
ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧

បច្ចេកទេសដាំក្តាត

ព័ត៌មាន និងចំណេះដឹងអំពីបរិស្ថាន កសិកម្ម និងសុខភាព

១. ការជ្រើសរើសពូជ

- ជ្រើសរើសយកមើមក្តាតណាដែលធំសម្រាប់ធ្វើពូជ។

២. ការរៀបចំដី

- ភ្ជួរលើកទី១ ដើម្បីកម្ចាត់ស្មៅ
- ភ្ជួរលើកទី២ ៨ថ្ងៃក្រោយភ្ជួរលើកទី១
- រាស់ដីលុបកម្ចាត់ស្មៅ និងធ្វើឱ្យដីស្មើ។

៣. ការដាំដុះ

- លើករងទទឹង ៥តឹក ចន្លោះពីរងមួយទៅរងមួយ ១ម៉ែត្រ
- ឆូតចង្អូរកណ្តាលរង ឬកាប់រណ្តៅទំហំ ១.៥តឹក ជម្រៅ ២-២.៥តឹក បួនជ្រុង គំលាតរណ្តៅមួយទៅមួយ ៥-៦តឹក
- ដាក់ជី (ជីលាមកសត្វ និងជីកំប៉ុស) រួចលុបវិញ
- ដាក់ដាំក្តាតនៅលើរង ឬរណ្តៅ។

៤. ការថែទាំ និងប្រមូលផល

- ស្រោចទឹកពេលដីស្ងួត
- ជ្រំគល់ ដកស្មៅ និងការពារសត្វចង្រៃ
- ដាក់ជីអ៊ុយរ៉េ ឬលាមកសត្វរៀងរាល់ ២សប្តាហ៍
- ប្រមូលផលបន្ទាប់ពីដាំបាន៦០ថ្ងៃ។

បច្ចេកទេសដាំដើមក្រូចឆ្មាវក្នុងលូស៊ីម៉ង់ត៍

១. ការរៀបចំដី

- លូស៊ីម៉ង់ត៍អង្កត់ផ្ចិត ៨តឹក មួយកង់
- លាយដីព្រៃមុខលើពុកផុយ ៣ភាគ ជាមួយធ្យូងអង្កាម លាមកសត្វពុកផុយ អង្កាមទន្ទ្រានខែត្រចិញ្ច្រាំ ម្សៅឆ្អឹងគោ សំបកគ្រាប់សណ្តែក មួយភាគ
- ដាក់ដីលាយក្នុងលូ រួចជាន់បង្ហាប់
- ពូនដីឱ្យក្រពង់កណ្តាលទុកឱ្យក្លាយជាដីកំប៉ុស
- ជីករណ្តៅកណ្តាលលូ ជម្រៅ ២តឹក

២. ការដាក់ដី

- ដាក់ដីកសិកររំខ្មែរ ១កំប៉ុង ម្សៅឆ្អឹង ១/២ កំប៉ុង ទឹកដោះគោ ឬដី NPK ១០០ក្រាម ដីកំប៉ុស ០,៥-១គ.ក្រ/រណ្តៅ ទ្រាប់បាតរណ្តៅ
- លុបដី បង្ហាប់មួយជាន់
- ដាក់ដីកសិកររំខ្មែរ ១/២កំប៉ុងម្សៅឆ្អឹង ១ក្តាប់ដៃ
- លុបដីបង្ហាប់ឱ្យណែន

៣. ការដាំដុះ

- ដាក់ដាំឫសមែកក្រូចឆ្មារដែលបានផ្សាំដុះ ឫស កណ្តាលរណ្តៅ រួចសង្កត់ឱ្យណែន
- ស្រោចទឹក រួចដោតឈើបង្គោល ចងផ្គោបមែកឈើដែលដាក់ដាំ
- គ្របកំណ្លោកលើគល់វា។

កំណត់ចំណាំ

I. វិធីកាត់មែក និងស្លឹក

១.ការកាត់មែក និងស្លឹក

- កាត់មែកតូចៗ ស្លឹកចាស់ និងស្លឹកមានជំងឺ (គួរកាត់នៅខែឧសភា ឬមិថុនា គឺកាត់មួយខែមុនក្រូចចេញផ្កា)។

២.ការដាក់ជី

- ស្រោចទឹក ដាក់ជីអ៊ុយរ៉េ ១គ.ក្រ លាយទឹក ២០លីត្រ
- ពេលក្រូចលាស់ស្លឹក និងផ្កាកំឡុងខែកញ្ញា និងតុលា ត្រូវស្រោចទឹក និងដាក់ជី 20-14-14 ចំនួន ២០០-៣០០ក្រាម ក្នុង១ដើម
- ពេលក្រូចចេញផ្កា លាយប៊ីចេង ១ស្លាបព្រាកាហ្វេ ជាមួយទឹក ១លីត្រ បាញ់លើផ្កា។
- ពេលក្រូចចេញក្តឹប ដាក់ជី 15-15-15 ឬ 16-16-16

៣.ការប្រមូលផល

- អាចប្រមូលផលនៅខែកុម្ភៈ
- ពេលប្រមូលផលអស់រួចរាល់ ក្នុងកំឡុងខែឧសភា ត្រូវដាក់ជី 15-15-15 ដើម្បីបំប៉នដើម សម្រាប់រដូវកាលក្រោយ។

II. វិធីគ្រី (ចិតក្រឡឹង)

១.ការកាត់មែក និងស្លឹក

- គ្រី (ចិតក្រឡឹង) ជុំវិញដើមក្រូចឆ្មារ មុខកាត់ ១ស.ម (ក្រូចឆ្មារដែលមានអាយុចាប់ពី ៣ឆ្នាំឡើងទៅ និងដាំដោយមែក)
- គ្រីបីកន្លែង ចន្លោះ១តឹកពីគ្នា កម្ពស់ ៥តឹក ឬ១ម ពីដី។

២.ការដាក់ជី

- ស្រោចទឹក និងដាក់ជីលាមកសត្វឱ្យបានជិតដល់ ពិសេសមួយខែមុនពេលក្រូចឆ្មារចេញផ្កា។

*សូមសាកល្បងលើមែកក្រូចឆ្មារ ១ឬ២ សិន។ ប្រសិនបានលទ្ធផលល្អសឹមអនុវត្តបន្ថែម។

១. ការរៀបចំផ្សាំ ដំណាក់កាលទី១

- កាត់ស្រកីដូង មុខកាត់ ២,៥-៣ស.ម និងប្រវែង ប្រមាណ ៦ស.ម
- ជ្រលក់ក្នុងទឹកទុកឱ្យសើមជោក
- ចងកៅស៊ូព័ទ្ធជុំវិញស្រកីដូង
- ចោះរន្ធផ្នែកខាងលើស្រកីដូង
- ទុកមែកជាប់ស្លឹកក្រូចឆ្មារដែលខ្ចីល្មម (ស្លឹកមិនចាស់ពេក) ប្រវែង ២ស.ម
- កាត់ស្លឹកក្រូចឆ្មារពាក់កណ្តាលខាងលើចោល
- ឆូតកាំបិតតាមបណ្តោយមែក ដែលជាប់ស្លឹកនោះ ២ឬ ៣ឆ្នូត
- ជ្រលក់មែកក្រូចឆ្មារនោះក្នុងទឹកថ្នាំជំនួយបន្តិច
- ដោតចូលក្នុងរន្ធស្រកីដូង ។

២. ការរៀបចំផ្សាំ ដំណាក់កាលទី២

- ដាក់ក្នុងរោងក្រោមម្លប់ដើមឈើ ព័ទ្ធជុំវិញចង់ប្លាស្ទិច ជុំវិញបិទជិត
- រៀបចំប្រព័ន្ធចំហាយទឹក បាញ់ស្រោចពីលើ
- បើកចំហាយទឹក ១ថ្ងៃ ៣ដង ព្រឹក ថ្ងៃ ល្ងាច។ ម្តង១០នាទី
- រយៈពេល ១ខែ ពេលចេញឫស យកក្រូចឆ្មារនោះទៅបណ្តុះក្នុងចង់ប្លាស្ទិច
- ២-៣ខែក្រោយ អាចយកទៅដាំបាន។

* ការបណ្តុះដោយប្រើស្លឹក អាចបានកូនច្រើនជាងការផ្សាំមែក។

កំណត់ចំណាំ

បច្ចេកទេសដាំក្រូចឆ្មារ តាមវិធីបង្កាត់ពូជ ខ្មែរ-ជប៉ុន

១. ការជ្រើសរើសពូជ

- យកពូជក្រូចឆ្មារក្នុងស្រុកផ្សាំជាមួយពូជក្រូចឆ្មារពីជប៉ុន
- យកពូជក្រូចឆ្មារពីជប៉ុនធ្វើជើងទម្រ។

* ពូជក្រូចឆ្មារក្នុងស្រុក យកក្រូចឆ្មារណាដែលមានផ្លែធំ សំបកស្តើង គ្រាប់តិច ទឹកច្រើន ធន់នឹងជំងឺ
* ពូជក្រូចឆ្មារពីជប៉ុន ឆាប់លូតលាស់រហ័ស ធន់អាកាសធាតុ តែរសជាតិមិនសូវឆ្ងាញ់។

២. ការរៀបចំដី

- ភ្ជួរដីឱ្យរាបស្មើ
- កាប់រណ្តៅទំហំ កន្លះម៉ែត្របួនជ្រុង
- គំលាតពីរណ្តៅមួយទៅរណ្តៅមួយប្រវែង ៥-៦ម។

៣. ការរៀបចំដាំ និងដាក់ជី

- បង្កាត់បាន ៦-៧ខែ យកទៅដាំក្នុងរណ្តៅដែលបានត្រៀម

ព័ត៌មាន និងចំណេះដឹងអំពីបរិស្ថាន កសិកម្ម និងសុខភាព
អាចទាញយកបានពី Facebook: អ៊ាង សុផល្លែត Sophalleth

- ដាក់ជីលាមកសត្វ ឬជីកំប៉ុសក្នុងរណ្តៅ
- កប់គល់ ១តឹក រួចលុបដី
- ស្រោចទឹកមួយថ្ងៃ ២ដង ព្រឹក ល្ងាច
- ដាក់ជីសរីរាង្គ ឬជីធម្មជាតិ ។

៤. ការប្រមូលផល

- រយៈពេល ២ឆ្នាំ ទើបអាចទទួលផល ។

៥. ការថែទាំបន្ទាប់ពីប្រមូលផល

- បន្ទាប់ពីប្រមូលផលក្រូចលើកទី១ ក្រូចនឹងចេញផ្លែផ្កាជាបន្តបន្ទាប់ មិនប្រកាន់រដូវ
- កាត់មែកដែលងាប់ ឬធ្វើឱ្យចង្អៀតដើម
- ត្រូវការពារក្រូចឆ្មារកុំឱ្យឆ្លងជំងឺ
- សំអាតស្មៅ
- ជីករណ្តៅក្បែរគល់ ដើម្បីឱ្យដក់ទឹក
- ដាក់ជីសរីរាង្គ ដែលមានសមាសធាតុប៉ូតាស្យូមខ្ពស់ ។

* ដីទំហំ ១ហ.ត អាចដាំក្រូចឆ្មារបានចំនួនពី ៤០០ ទៅ ៦០០ដើម។

១. ការរៀបចំដី

- ដាំលើដីស្ងួត គ្មានដក់ទឹក ឬជាំទឹក
- ភ្ជួរ ឬកាប់ដីជម្រៅ ២-៣តឹក
- បំបែកដីឱ្យម៉ដ្ឋ
- លើករងទទឹង ១ម បណ្តោយតាមទំហំដី កម្ពស់ ៣តឹក

* ដំណាំមើមភាគច្រើន មិនសូវរើសដីទេ ប៉ុន្តែដីដែលដាំបានល្អជាងគេ គឺដីល្បាយខ្សាច់ (ដីធូរ ស្រស់ទឹក និងមានជីជាតិ)។ តំបន់ដីឥដ្ឋ ដំណាំមើមពុំសូវឱ្យទិន្នផលខ្ពស់ទេ ព្រោះស្អិតណែន មិនអាចរីកធំធាត់បាន។

២. ការរៀបចំដាំ

- បណ្តុះមើមចាស់រួចយកទៅដាំ
- ដាំគំលាតពីគុម្ពមួយទៅគុម្ពមួយប្រវែង ៣តឹក។

៣. ការថែទាំ

- ដាក់ជីពេលដាំបាន ២-៣ ខែ (ពេលបែកគុម្ពច្រើន)

- បោចស្មៅ ជ្រំដី និងពូនគល់ (ហាមប៉ះគល់)

* ខ្ជាយដុះលូតលាស់បានល្អប្រសើរ ក្នុងកម្រិតទឹកល្មម

* ខ្ជាយជាដំណាំដែលសត្វល្អិតមិនយាយី។

៤. ការប្រមូលផល

- ពេលស្លឹកទុំ ហើយស្វិត បញ្ជាក់ថា មើមខ្ជាយចាស់។

* ខ្ជាយត្រូវការពន្លឺថ្ងៃខ្លី ទើបលូតលាស់ល្អ និងផ្តល់ទម្ងន់ធ្ងន់។ ទិន្នផលមើមអាចថយចុះពេលពន្លឺថ្ងៃចាំងលើរងយូរពេក លើសពី១២ម៉ោងក្នុងមួយថ្ងៃ។

* អាចកប់ចោលក្នុងដី ១ឆ្នាំ ក៏មិនខូចដែរ។

កំណត់ចំណាំ

១. ការរៀបចំសម្ភារ

- បាវប្រភេទ ២៥ ឬ ៥០គីឡូក្រាម
- ពូជមើមខ្ញី ដែលដុះពន្លក
- ដីស្រែស្រទាប់លើ លាយជាមួយជីកំប៉ុស និងកម្ទេចស្លឹកឈើ។

២. ការរៀបចំដាំ

- ចំពោះប្រភេទបាវ ៥០គីឡូក្រាម បត់ត្រឹមពាក់កណ្តាល
- ចំពោះប្រភេទបាវ ២៥គីឡូក្រាម មិនបាច់បត់
- ដាក់គំលាតពីបាវមួយទៅបាវមួយ ប្រវែង ៥តឹក ឬអាចដាក់ជាប់គ្នាក៏បាន
- ដាក់ដាំមើមខ្ញីកណ្តាលបាវ ជម្រៅកន្លះតឹក
- គ្របចំបើងលើគល់ខ្ញី
- ដាក់បាវខ្ញីនៅកន្លែងមានពន្លឺគ្រប់គ្រាន់ និងមិនលិចទឹក។

៣. ការថែទាំ

- ស្រោចទឹកជាប្រចាំ
- ដាក់បន្ថែមទឹក ជីកំប៉ុស រាល់ ២អាទិត្យម្តង
- សំអាតស្មៅ។

៤. ការប្រមូលផល

- អាយុបាន ៤-៥ខែ អាចប្រមូលផលបាន។

កំណត់ចំណាំ

បច្ចេកទេសដាំខ្ទឹមបារាំងក្នុងដបប្លាស្ទិក

១. ការរៀបចំសម្ភារ

- ដបទឹកសុទ្ធ ឬដបទឹកក្រូចប្លាស្ទិក
- កន្ត្រៃ
- គ្រាប់ខ្ទឹមបារាំងដែលមានពន្លក
- ដីលាយកម្ទេចស្លឹកឈើ និងលាយជីលាមកសត្វ។

២. ការរៀបចំដាំ

- ចោះរន្ធជាថ្នាក់ៗប៉ុនមេជើង ជុំវិញដប (សូមមើលរូប)
- ដាក់បំពេញដីត្រឹមរន្ធក្រោមគេ
- ដាក់ដាំគ្រាប់ខ្ទឹមបារាំងខាងមានពន្លកមកក្រៅរន្ធ (សូមមើលរូប)
- ដាក់ដាំរបៀបនេះរហូតគ្រប់រន្ធ។

៣. ការថែទាំ

- ស្រោចទឹកឱ្យសព្វ
- ដាក់នៅកន្លែងមានពន្លឺ
- ស្រោចទឹករាល់ព្រឹករហូតបានផល។

១. ការត្រៀមពូជដាំ

- ហាលពូជខ្ទឹមស រយៈពេល ១ខែ

* ផ្ទៃដីទំហំ ៧អា ដាំពូជអស់ចំនួន ១៧គ.ក។

២. ការរៀបចំដី និងការដាំ

- ភ្ជួររាស់ដី និងហាលឱ្យឆ្អិន
- លើករងទទឹង ១ម បណ្តោយតាមទំហំដី និង កម្ពស់ ២.៥តឹក។

៣. ការរៀបចំដាំ

- ដាក់ជីលាមកសត្វពុកផុយពី ១,៥-២គ.ក្រ/ម២ ទ្រាប់បាតរង
- កប់មើមខ្ទឹមជម្រៅរាក់ៗ រួចលុបដីពីលើ
- ទុកចន្លោះដាំពីមួយគ្រាប់ទៅមួយគ្រាប់ ប្រវែង ២តឹក។

៤. ការថែទាំ

- ស្រោចទឹកឱ្យជោក ក្រោយដាំ និងពេលខ្ទឹមដុះ
- កាត់ចំបើងខ្លីៗ គ្របលើរងតាមចន្លោះគុម្ព
- ស្រោចទឹកមួយថ្ងៃ២ដង ព្រឹក និងល្ងាច

- ជ្រុំដី ដកស្មៅ។

៥. ការប្រមូលផល

- ចាប់ពី ៣ខែឡើង អាចប្រមូលផលបាន។

* ផ្ទៃដី ៧អា អាចប្រមូលផលបាន ៥៦០គ.ក្រ។

កំណត់ចំណាំ

១. ការជ្រើសរើសពូជ

- កូនចេកដែលធំល្មម អាយុប្រមាណ ៥ខែ
- កាត់ដើមខាងលើចោល ទុកប្រវែង ៤តឹក ពីគល់។

២. ការរៀបចំដាំ

- ជីករណ្តៅទំហំ ៣តឹកx ៣តឹកx ជម្រៅ ៥តឹក
- ដាក់ជីស្លឹកឈើ និងអង្កាម ៥គ.ក្រ ក្នុង១រណ្តៅ
- ដាក់ដាំចេកគល់ឡើងលើ នៅចន្លោះកណ្តាលរណ្តៅ
- លុបដី ប្រមាណកន្លះតឹក
- គ្របចំបើង លើរណ្តៅ
- ស្រោចទឹក។

៣. ការប្រមូលផល

- ប្រមាណ ៨ខែ អាចប្រមូលផលបាន។

* ការដាំបែបនេះ ចំណេញបានកូនច្រើន ដើមទាបជាងការដាំធម្មតា។
* សូមសាកល្បងដាំតាមវិធីនេះ២ឬ៣ដើមសិន។ ប្រសិនបានផលល្អ សឹមដាំច្រើនជាងនេះ។

១. ការរៀបចំពូជ

- ហាលគ្រាប់ពូជក្រោមថ្ងៃក្តៅរយៈពេល ២ ឬ ៣ ម៉ោង
- ដាក់ត្រាំទឹក ៣ ឬ ៤ម៉ោង។

២. ការរៀបចំដី

- ភ្ជួរដី ២-៣ដង ដើម្បីអោយដីធូរ និងជ្រាបទឹកបានល្អ
- លើករងទទឹង១ ឬ ១.២ម បណ្តោយតាមទំហំដី និង កម្ពស់ ២.៥ ឬ ៣តឹក
- ចន្លោះពីរងមួយទៅរងមួយប្រវែង ២តឹក
- លាយជីប្រភេទប៉ូតាស្យូម ១៥០-២០០គ.ក្រ ជាមួយជីផ្សំជាមួយអង្កាមដុត១៥-១៨ត/ហ.ត
- បាចលើរង
- រាស់ឈុប និងកៀរអោយស្មើ។

៣. ការរៀបចំដាំ

- កប់គ្រាប់ពូជលើរងក្នុងជម្រៅ ២ស.ម (ជាមធ្យម ដាក់ ២គ្រាប់ក្នុងមួយគុម្ព)

- ដាំចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែង ២តឹក
- គ្របចំបើងស្ងួត ៧០ ទៅ ៨០%នៃផ្ទៃរង
- ស្រោចទឹកឱ្យជោកក្រោយដាំរួច។

៣. ការថែទាំ

៣.១.ការស្រោចទឹក

- ពេលដុះពន្លកត្រូវការសំណើមថេរ តែមិនត្រូវការទឹកជាំទេ
- ពេលដុះស្លឹក ២-៣សន្លឹក (៩-១០ថ្ងៃ) ត្រូវការទឹកកម្រិតមធ្យម
- ពេលមើមរីកធំធាត់ (១៥-១៨ថ្ងៃ) ត្រូវស្រោចទឹកកាន់តែច្រើន។

៣.២. ការជ្រំដី និងដកស្មៅ

- ក្រោយដាំបាន ១៥-១៨ថ្ងៃ ជ្រំដី
- ដករំលស់កូន ទុកតែ ១ដើម/គុម្ព
- ដកស្មៅ និងជ្រំគល់
- ផ្អាកការស្រោចទឹក១ថ្ងៃ ឱ្យស្ងួតដី។

៣.៣.ការដាក់ជី

- លើកទី១ រយៈពេល ១០ថ្ងៃ ក្រោយដាំ៖ មេជី (អ៊ុយរ៉េ) ១គម្រប មេថ្នាំបណ្តេញសត្វល្អិត ១ គម្រប មេអ័រម៉ូន ១គម្រប ទឹក ១០លីត្រ
- លើកទី២ រយៈពេល ១៥-១៨ថ្ងៃក្រោយដាំ៖ មេជី(អ៊ុយរ៉េ) ១គម្រប មេថ្នាំបណ្តេញសត្វ ល្អិត ១គម្រប មេអ័រម៉ូន ១គម្រប ទឹក ១០លីត្រ
- លើកទី៣ ក្រោយដាំបាន ២៥-៣០ថ្ងៃ ប្រើ មេជី(អ៊ុយរ៉េ) ១គម្រប មេថ្នាំបណ្តេញសត្វ ល្អិត ១គម្រប មេអ័រម៉ូន ២គម្រប ទឹក ១០លីត្រ
- លើកទី៤ ក្រោយដាំ ៤០ថ្ងៃ មេជី(អ៊ុយរ៉េ) ១គម្រប មេថ្នាំបណ្តេញសត្វល្អិត ១គម្រប មេអ័រម៉ូន ២ គម្រប ទឹក ១០លីត្រ។

៤.ការប្រមូលផល

- ពេលស្លឹកប្រែពណ៌ពីខ្ចីទៅបៃតងចាស់
- កំពូលត្រួយលែងលូតលាស់
- មើមប្រែពីសខ្ចី ទៅប្រផេះ។

* ទិន្នផលអាស្រ័យលើប្រភេទពូជ និងរដូវកាលដាំដុះ។ ជាមធ្យមទទួលបានទិន្នផលពី ២៨-៣២ត/ហ.ត។

កំណត់ចំណាំ

ដំណាំឆៃថាវងាយដាំ ត្បិតជាបន្លែមើមដែលចូលចិត្តអាកាសធាតុត្រជាក់បន្តិច មិនក្តៅហែង។ បើបានដីធូរលាយខ្សាច់ ឆៃថាវនឹងរហ័សធំ ពិសេសឆៃថាវ ជាដំណាំដែលត្រូវការទឹកច្រើន។

ឆៃថាវមានពីរប្រភេទ គឺពូជមានរយៈពេល ៦០ ថ្ងៃ និង ៤៥ថ្ងៃ។ ពូជ ៦០ថ្ងៃ ភាគច្រើនគេដាំនៅរដូវប្រាំង និងពូជ ៤៥ថ្ងៃ ដាំនៅរដូវវស្សា ប៉ុន្តែពូជទាំងពីរនេះ កំពុងពេញនិយមលើទីផ្សារប្រចាំថ្ងៃដូចគ្នា។

១.ការរៀបចំដី

- បាចជីលាមកសត្វលាយផេះ ឬជីកំប៉ុស
- ហាលដីចោល ១សប្តាហ៍
- គួរភ្ជួរដីយ៉ាងហោច ៣-៤លើក ឱ្យដីធូរ និងងាយជ្រាបទឹក
- លើករងទទឹង ១.៨ម បណ្តោយតាមទំហំដីកម្ពស់ ១តឹក។

២. របៀបដាំ

- **វិធីទី១**
  - ជីករណ្តៅទំហំ ១តឹក ជម្រៅវាក់ៗ(ប្រហែល ១ចំអាមដៃ)
  - ដាក់គ្រាប់ពូជ ២-៣គ្រាប់ ក្នុងមួយរណ្តៅ។
- **វិធីទី២**
  - ព្រោះគ្រាប់ពូជលើរង
  - បាចជីលាមកសត្វឱ្យលុបគ្រាប់ពូជ ប្រមាណ ១ថ្នាំងម្រាមដៃ
  - គ្របចំបើង ឬស្មៅស្ងួតស្តើងៗមួយស្រទាប់
  - ពេលដុះស្លឹកមួយដើម ៥សន្លឹក ដកដើមដែលមិនល្អចោល
  - ទុកចន្លោះពីមួយដើមទៅមួយដើម ប្រមាណ ១ចំអាម ឬ ៣តឹក។

៣. ការថែទាំ

- ស្រោចទឹក ១ថ្ងៃ ម្តង ពេលថ្ងៃ ខែប្រាំង។ ជាធម្មតាគ្រាន់តែស្រោចទឹកឱ្យសើមៗប៉ុណ្ណោះ
- បោចស្មៅ ជ្រួយដី។

៤.ការប្រមូលផល

- ៤៥ឬ៦០ថ្ងៃ អាចប្រមូលផលបាន។រយៈពេលនៃការប្រមូលផលអាស្រ័យលើពូជដែលដាំ។

* ឆែថាវមានរសជាតិផ្អែមជាងធម្មតា ដោយសារការប្រើប្រាស់ជីធម្មជាតិ មិនប្រើជីគីមី។

កំណត់ចំណាំ

ជីវ៉ាន់ស៊ុយមាន ២ប្រភេទ គឺពូជស្លឹកឆៃកធំៗ និងពូជស្លឹកឆៃកតូចៗល្មម។ ប្រភេទពូជជីវ៉ាន់ស៊ុយស្លឹកឆៃកធំៗ គឺជាពូជដែលពេញនិយមលើទីផ្សារប្រចាំថ្ងៃ។

១. ការរៀបចំដី

- ភ្ជួរដីហាល ៣-៤ថ្ងៃ រួចភ្ជួរឱ្យម៉ដ្ឋ
- លើករងទទឹង ៨តឹក បណ្តោយតាមទំហំដីកម្ពស់ ១តឹក
- សងខាងរងត្រូវលើកដីឱ្យខ្ពស់ជាងផ្នែករងកណ្តាល
- ពង្រាបដីកណ្តាលរងឱ្យស្មើ។

២. ការរៀបចំដាំ

- កិនបំបែកគ្រាប់ពូជជីវ៉ាន់ស៊ុយ
- ព្រោះគ្រាប់ពូជលើរង
- ដាក់ដីកំប៉ុស ដីដំបូក
- គ្របចំបើងពីលើ
- ស្រោចទឹក។

៣. ការថែទាំ

- ស្រោចទឹក ១ថ្ងៃ ២ដង ព្រឹក និងល្ងាច
- បោចស្មៅ ជ្រួយដី។

* ជីវ៉ាន់ស៊ុយលូតលាស់មិនសូវល្អ បើប្រើជីគីមី។

៤. ការប្រមូលផល

- ក្រោយដាំបាន ៩០ថ្ងៃ អាចប្រមូលផលបាន។

កំណត់ចំណាំ

១. ការជ្រើសរើសពូជ

- ជីដែលមានខ្នែងល្អ
- បេះស្លឹកចេញខ្លះ ទុកត្រឹម ៣-៤ស្លឹក

២. ការរៀបចំដាំ

- រៀបចំថាស (ជ័រ ឬស្មោ) ដែលមានរន្ធតំរៀបគ្នា (សូមមើលរូប)
- លាយកម្ទេចថ្មពណ៌សជាមួយកម្ទេចថ្មភ្នំភ្លើង ឬគ្រាប់ខ្សាច់ធំ ដាក់ក្នុងរន្ធថាសពាក់កណ្តាល
- ប្រើចន្លាសចាប់ដើមជីអង្កាម ដាក់ដាំក្នុងរន្ធ កុំឱ្យជាំ ឬបាក់ខូច
- យកថាសនោះដាក់ក្នុងកញ្ច្រែង
- ចាក់ទឹកចូលពាក់កណ្តាលរន្ធ
- ដាក់នៅកន្លែងមានពន្លឺថ្ងៃតិចៗ

៣. ការថែទាំ

- ៧-១០ថ្ងៃ ឬពេលជីអង្កាមលាស់ត្រួយ ត្រូវដាក់ជី (លាមកប្រចៀវ ១គ.ក្រ លាយទឹក២លីត្រ កូរឱ្យសព្វ ហាលថ្ងៃ ៣ថ្ងៃ។ យកទឹក

ជីលាយជាមួយទឹក ២០លីត្រ សម្រាប់ស្រោច)

៤. ការប្រមូលផល

- ៣-៤ អាទិត្យ អាចប្រមូលផលបានហើយ។

កំណត់ចំណាំ

១. ការរៀបចំដី

- ដីមានល្បាយខ្សាច់ និងមមោក (ដីមានកម្ទេចស្មៅ ឫសស្មៅ ស្លឹកឈើដែលពុកផុយរលួយ ក្លាយជាល្បាប់ក្រាស់)
- ភ្ជួរដី ២-៣ដង។

២. ការរៀបចំដាំ

- លើកពូនរង ទទឹង ១ម បណ្តោយតាមទំហំដីកម្តស់ ៣តឹក។ គំលាតពីរងមួយទៅរងមួយប្រមាណ ១ម
- កាយចង្អូរចន្លោះកណ្តាលបណ្តោយរង
- ដាក់ជីលាមកគោ និងជីកំប៉ុស ផេះអង្កាម ហើយលុបវិញ
- ដាំពូជដំឡូង ចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែង ២តឹក។

៣. ការថែទាំ

- ស្រោចទឹក ពេលដីស្ងួត។ ខែវស្សាមិនចាំបាច់ស្រោចទឹកញឹកញាប់ពេកទេ

- កុំឱ្យមាន់ ឬសត្វផ្សេងៗ ចូលកាយ បណ្តាលឱ្យខូចខាតដំឡូង
- សំអាតស្មៅ។

៤. ការប្រមូលផល

- រយៈពេលប្រមាណ ៤ខែ អាចប្រមូលផលបានហើយ។

កំណត់ចំណាំ

១. ការរៀបចំពូជ

- បណ្តុះគ្រាប់ពូជដំឡូងបារាំង
- រក្សាទុកឃ្លាតពីគ្នា នៅកន្លែងមានកម្តៅថ្ងៃគ្រប់គ្រាន់។

២. ការរៀបចំដាំ

- ជ្រួយដី ដាក់ជី ស្រទាប់ដីខាងលើ
- ពូនដីកម្ពស់ ៨ស.ម ។ គំលាតពីជួរមួយទៅមួយប្រវែង ២៥-៣៥ស.ម
- ប្រមូលកម្ទេចដុំដី និង ស្មៅចេញ
- ដាំដំឡូងបារាំងគំលាតពី ១ដើម ទៅ ១ដើម ប្រវែង ៣០ស.ម។

៣. ការថែទាំ

- ស្រោចទឹកឱ្យទៀងទាត់
- ពេលដំឡូងបារាំង ដុះបានកម្ពស់ប្រហែល ៥ ទៅ ១០ស.ម ត្រូវជ្រួយដី និងដាក់ជីបន្ថែម។

៤. ការប្រមូលផល

- ស្លឹករីកបៃតងល្អ ឬសប្រែពណ៌ទៅជាពណ៌លឿង អាចប្រមូលផលបានហើយ។

កំណត់ចំណាំ

១. ការជ្រើសរើសពូជ

- ពូជមានអាយុពី ១០ - ១២ខែ
- ដើមមានភ្នែកល្អ (ភ្នែកច្រើន) ដើមធំល្មម
- កាត់ដើមប្រវែង ៣តឹក ដោយម៉ាស៊ីនកាត់ ឬ កាំបិតដែលមុត
- វិធីធ្វើឱ្យដំឡូងមានមើមច្រើនជាន់ (ចេញមើមច្រើនថ្នាក់)
  - បង្វិលភ្នែកចុះក្រោម
  - យកកាំបិតកាប់ដើមដំឡូង ឱ្យមានស្នាមមុខកាំបិត ប្រហែល ៩ស្នាម (ស្នាម ២ភាគនៃកំណាត់ដើម)
- យកទៅត្រាំទឹកជី
  - ទឹកជី ប្រភេទ Chitosan ១០ ម.ល.
  - ទឹកជីមានសារធាតុដែកខ្ពស់ ២០ ម.ល.
  - លាយជាមួយទឹក ២០លីត្រ
  - ត្រាំទុករយៈពេលចាប់ពី ១០ - ២០នាទី

*អត្ថប្រយោជន៍នៃការត្រាំដើមពូជ

- បន្ថែមសារធាតុអាហារឱ្យដើមពូជ
- ជំរុញឱ្យឆាប់ដុះលូតលាស់ និងឫសច្រើន
- ការពារកុំឱ្យសត្វល្អិតមកបៀតបៀន
- ការពាររោគដែលជាប់មកជាមួយដើមពូជ។

២. ការរៀបចំដី

- ភ្ជួរហាលដីក្នុងចន្លោះពី ៧-១០ថ្ងៃ មុននឹងធ្វើការដាំដុះ។

៣. ការរៀបចំដាំ

- លើករងចន្លោះពីរងមួយទៅរងមួយ ប្រវែង ១.២៥ម ឬ ១.៥០ម
- ដោតដើមពូជឱ្យត្រង់លើរងជម្រៅ ២តឹក ទុកដើមពូជឱ្យសល់ឡើងលើប្រវែងប្រមាណ ១តឹក
- ចន្លោះពីគុម្ពមួយទៅគុម្ពមួយ ប្រវែង ១ម

*ផ្ទៃដី ១ហ.ត ប្រើពូជអស់ ប្រហែល ៨ពាន់ទៅ ១ម៉ឺន កំណាត់។

ព័ត៌មាន និងចំណេះដឹងអំពីបរិស្ថាន កសិកម្ម និងសុខភាព

៤. ការថែទាំ

- បាញ់ថ្នាំគីមី ការពារកុំឱ្យស្មៅដុះ (ថ្នាំការពារ និងថ្នាំសំលាប់ស្មៅ)
- រូបមន្តប្រើប្រាស់ថ្នាំ៖
  - កម្រិតនៃការប្រើ ៥០ក្រាម លាយជាមួយទឹក ២០លីត្រ
  - កម្រិតនៃការប្រើ ១២៥០ក្រាម លាយជាមួយទឹក ៥០០លីត្រ សំរាប់ផ្ទៃដី ១ហ.ត
  - ដាំរួចចាប់ផ្តើមបាញ់ភ្លាម
  - ចាប់ផ្តើមបាញ់ម្តងទៀតនៅពេលដំឡូងមានអាយុ ៣ខែ
- ការបាញ់ថ្នាំជំនួយស្លឹក និងដើម (ប្រសិនបើមានវត្តមានសត្វល្អិតស៊ី ឬពពួកចៃ មមាចត្រូវលាយជាមួយ ថ្នាំគីមីផ្សេងទៀត)
  - ជីទឹកប្រភេទ Chitosan ១០ម.ល
  - ជីទឹកដែលមានសារធាតុដែកខ្ពស់ ២០ម.ល
  - ថ្នាំសម្លាប់សត្វល្អិត

- បាញ់ថ្នាំលាយនេះ ៥ដង
  - លើកទី១ ពេលចាំផ្តើមដាំ
  - លើកទី២ អាយុបាន ១៥ថ្ងៃ
  - លើកទី៣ អាយុបាន ៣០ថ្ងៃ
  - លើកទី៤ អាយុបាន ៦០ថ្ងៃ
  - លើកទី៥ អាយុបាន ៩០ថ្ងៃ។

៥. ការដាក់ជី

- លើកទី១ មុនពេលដាំ។ ដាក់ជីកំប៉ុស ចំនួន ១៥-២០គ/ហ.ត លាយជាមួយផេះអង្កាម និង ជី ១៥.១៥.១៥ ទ្រាប់បាត
- លើកទី ២ ពេលអាយុបាន ១ខែ
  - សំអាតស្មៅ
  - ភ្ជួរដី ជ្រួយគល់
  - ដាក់ជី ១២៥ គ.ក្រ ក្នុង ១ហ.ត
  - ភ្ជួរដីកប់ជីលុបគល់ ។

៦. ការរីកធំធាត់

- ដំណាក់កាលទី ១៖ អាយុបាន ២ - ៣សប្តាហ៍ ដំបូង ចាប់ផ្តើមរីកលូតលាស់
- ដំណាក់កាលទី ២៖ អាយុបាន ២ខែ ចាប់ផ្តើម បែកមែកធាង និងស្លឹក
- ដំណាក់កាលទី ៣៖ អាយុចាប់ពី ៣ខែឡើង ឬសចាប់ផ្តើមស្រូបយកធាតុអាហារ ដើម្បីយកទៅចិញ្ចឹមមើមឱ្យមានម្សៅ
- ដំណាក់កាលទី ៤៖ អាយុបាន ១៤ខែ ជ្រុះស្លឹក គឺដំឡូងពុំអាចរីកលូតលាស់បានទេ
- ដំណាក់កាលទី ៥៖ អាយុចាប់ពី ១៤ខែឡើង ចាប់ផ្តើមរីកលូតលាស់សាជាថ្មីម្តងទៀត។ មើមធំ ប៉ុន្តែមិនសូវមានម្សៅ ពីព្រោះជាតិម្សៅត្រូវទៅចិញ្ចឹមស្លឹក ដើម្បីឱ្យស្លឹករីកលូតលាស់ជាថ្មី។

*បច្ចុយ ៨ប្រការ ដែលអាចជួយបង្កើនទិន្នផលដំឡូងមី៖

១. សណ្ឋានដី

២. កំណាត់ពូជ

ព័ត៌មាន និងចំណេះដឹងអំពីបរិស្ថាន កសិកម្ម និងសុខភាព

ចាញ់យកឯកសារពី
eangsophalleth.com
SOPHALLETH

៣. ទឹក
៤. ពន្លឺថ្ងៃ
៥. អាកាសធាតុ
៦. រោគ និងសត្វល្អិត
៧. ជីនិងថ្នាំ
៨. ការមើលថែទាំ។

កំណត់ចំណាំ

១. ការរៀបចំពូជ

- ត្រាំគ្រាប់ពូជក្នុងទឹកមួយយប់
- ស្រង់មករក្សាទុកមួយថ្ងៃ មុនយកទៅដាំ។

២. ការរៀបចំដី

- ភ្ជួរដី ២-៣ដង ឱ្យដីម៉ដ្ត និងធូរ

* ប្រភេទដីដែលល្អសម្រាប់ដំណាំត្រកួន គឺជាប្រភេទដីធូរ មានលាយល្បាយខ្សាច់។

៣. ការរៀបចំដាំ

- រៀបចំរងទទឹងប្រមាណ ១ម បណ្តោយតាមទំហំដី
- លើកកូនភ្លឺតូចៗនៅចន្លោះរងនីមួយៗ ដើម្បីងាយស្រួលស្រោចទឹក និងប្រមូលផល
- លាយជីលាមកគោស្ងួតខ្លះ ដាក់តាមរងនីមួយៗ
- កាយចង្អូរកាត់ទទឹងរងជម្រៅប្រមាណ ១.៥ស.ម គំលាតពីចង្អូរមួយទៅចង្អូរមួយ ប្រវែងប្រមាណ ១.៣តឹក

- រាយគ្រាប់តាមចង្អូរដែលបានរៀបចំ គំលាតពីគ្រាប់មួយទៅគ្រាប់មួយ ប្រមាណ ២ស.ម
- លុបដីតាមចង្អូរ។

៤. ការថែទាំ

- ស្រោចទឹកពេលព្រឹកជាប្រចាំ
- ជ្រួយដីចន្លោះគល់ និងដកស្មៅ
- ថែមជីកំប៉ុសពុកផុយល្អ រាល់អាទិត្យ ឬ១០ថ្ងៃម្តង។

៥. ការប្រមូលផល

- រយៈពេលប្រមាណ ២០-២៥ថ្ងៃ អាចប្រមូលផលបាន។ អាចដកយកទាំងឫសតែម្តង។

កំណត់ចំណាំ

បច្ចេកទេសដាំត្រកួនដោយមិនប្រើប្រាស់ដី

I. វិធីទី១៖ ដាំក្នុងកញ្ជ្រែង

១. ការរៀបចំសម្ភារ

- គ្រាប់ត្រកួន
- កញ្ជ្រែង
- ធើង ឬធុងទឹកតូចល្មមអាចដាក់កញ្ជ្រែងចូលបាន
- ទឹកស្អាត លាយជីលាមកគោស្ងួត ឬជីលាមកប្រចៀវស្ងួតបន្តិច
- កម្ទេចស្រកីដូង (មិនប្រើក៏បាន)។

២. ការរៀបចំដាំ

- ដាក់ស្រកីដូងក្រាលបាត (មិនដាក់ក៏បាន)
- រាយគ្រាប់ត្រកួនក្នុងកញ្ជ្រែង
- ដាក់កញ្ជ្រែងចូលក្នុងធុង
- ចាក់ទឹកចូលធុងឱ្យលិចត្រឹមគ្រាប់
- ដាក់នៅកន្លែងមានពន្លឺគ្រប់គ្រាន់។

៣. ការប្រមូលផល

- រយៈពេល ២-៣ថ្ងៃ នឹងចាប់ផ្តើមដុះ

- រយៈពេលប្រមាណ ២សប្តាហ៍ ប្រមូលផលបានហើយ។

II. វិធីទី២៖ ដាំក្នុងផើង ធុង ឬកេសស្មោ

១. ការរៀបចំសម្ភារ

- កញ្ច្រែង កម្ពស់ប្រមាណ ១តឹក
- ផើង ធុង ឬកេសស្មោ កម្ពស់ប្រមាណ ៣តឹក អាចដាក់កញ្ច្រែងចូលបាន
- អេប៉ុង ឬស្រកីដូងចិញ្ច្រាំ សម្រាប់ដាក់ដាំគ្រាប់ត្រកួន
- ទឹកស្អាត
- គ្រាប់ត្រកួន។

២. ការលាយទឹកជី

- ជីលាមកប្រចៀវកន្លះគីឡូ លាយជាមួយទឹក២០លីត្រ កូរឱ្យសព្វ
- ហាលថ្ងៃ ៣ថ្ងៃ
- លាយទឹកជី១លីត្រ ជាមួយទឹក ១០លីត្រ សម្រាប់ដាំ។

ចាញ់យកឯកសារពី

eangsophalleth.com

SOPHALLETH

រ៉ាន សុផល្លែត sophalleth

បច្ចេកទេសដាំត្រប់ក្នុងផើង

១. ការរៀបចំសម្ភារ

- ផើង មានប្រហោងខាងក្រោម (ទំហំផើងល្មមនឹងដាក់ដាំដើមត្រប់)
- រៀបចំរោងបណ្តុះកូនត្រប់
- កូនត្រប់បណ្តុះអាយុ ២សប្តាហ៍ អាចដាំបាន។

២. ការរៀបចំដី

- ជីកអន្លង់សមល្មម
- ដាក់កំប៉ុសពុកផុយល្អ ក្នុងអន្លង់
- ចិញ្ច្រាំចំបើងខ្លីៗ ស្រកីដូង កំណ្តោកស្ងួត
- ប្រស់ទឹកឱ្យសើម
- ដាក់ចូលក្នុងអន្លង់ ទុកចោលយ៉ាងតិច ១ខែ
- កើបដីដែលបានលាយពីក្នុងអន្លង់ មកលាយជាមួយដីខ្មៅ ដីបាតបឹង ឬដីមានកម្ទេចរុក្ខជាតិរលួយ
- ហាលអោយស្ងួត ១អាទិត្យ
- ច្រកដីក្នុងផើង រួចដាក់ដាំ។

* ដីដាំត្រូវមានភាពរោយរសោះ មិនជាប់គ្នា។ បើមានលាមកគោច្រើនពេក អាចរោយដីប្រៃដំណាំឆាប់ងាប់ មិនមានផ្លែ។

៣. ការថែទាំ

- ស្រោចទឹកមួយថ្ងៃម្តង
- ដាក់ដំណាំនៅកន្លែងមានពន្លឺគ្រប់គ្រាន់ មិនសូវមានខ្យល់បក់ខ្លាំង ការពារកុំឱ្យបាក់ដើម។

កំណត់ចំណាំ

១. ការជ្រើសរើសពូជ

- គ្រាប់ថ្លោសល្អ និងមិនខ្ចីពេក យកទៅបណ្តុះ។

២. ការរៀបចំដី

- ភ្ជួរដី ២ ទៅ ៣ដង
  - ភ្ជួរលើកទី១៖ បាញ់ថ្នាំកំចាត់ស្មៅមុនភ្ជួរ។ ទុកចោល ៣ ទៅ ៧ថ្ងៃ
  - ភ្ជួរលើកទី២៖ រាស់អោយរាបស្មើ
- លើករងដាំ
- កាប់រណ្តៅដាំ ទំហំ ២តឹក បួនជ្រុង គំលាតពីរណ្តៅមួយទៅរណ្តៅមួយប្រវែង ០.៥-០.៧ម។

៣. ការរៀបចំដាំ

- ដាក់ដាំកូនត្រប់ (កូនត្រប់ដែលមានសុខភាពល្អ) ដែលបណ្តុះកម្ពស់ ១តឹក ក្នុងរណ្តៅដែលជីករួច
- ស្រោចទឹកឱ្យសើមល្មម។

៤. ការថែទាំ

- ស្រោចទឹក
- ជ្រំគល់ដកស្មៅ
- ការពាររោគបំផ្លាញ ពិសេស ពួកទ្រីប ថៃ ដែលជាភ្នាក់ងារចម្លងជំងឺវីរុស
- ក្តិចស្លឹកចាស់ៗ ឬមែកដែលគ្មានប្រយោជន៍ចេញ។

៥. ការប្រមូលផល

- រយៈពេល ១ខែកន្លះ អាចប្រមូលផលបាន។

កំណត់ចំណាំ

១. ការរៀបចំដីបណ្តុះកូន

- ធ្យូងអង្កាមត្រាំទឹក ២យប់ ទុកអោយស្រស់ ចំនួន ៣ធុងស្តេត្រូ
- ដីកំប៉ុសស្អូតល្អ ចំនួន ២ធុងស្តេត្រូ
- ដីកំប៉ុស ឬដីដំបូកម៉ដ្ឋល្អ ចំនួន ១ធុងស្តេត្រូ
- ច្របល់ដីទាំងនោះអោយសព្វ
- លីង ចំហុយ ឬច្រកថង់ ចងមាត់ឱ្យជិត ដាក់ក្រោមកម្តៅថ្ងៃ ១សប្តាហ៍ ទើបយកទៅបណ្តុះ

* PH ដីសមស្របសម្រាប់ដាំត្រប់ ចន្លោះពី ៥.៥ ទៅ ៦.៥

* សារប្រយោជន៍ការលាយល្បាយដីបណ្តុះកូន៖

- លូតលាស់ល្អ
- កូនបន្លែស្រូបយកជីជាតិបានគ្រប់គ្រាន់
- សម្លាប់មេរោគ (ជំងឺ) ដែលបង្កអោយកូនបន្លែរលួយ
- សម្លាប់គ្រាប់ស្មៅចង្រៃ
- សម្លាប់ពង និងសត្វល្អិតចង្រៃក្នុងដី។

២. ការធ្វើរោងបណ្តុះកូន

ទំហំរោង៖

- កម្ពស់ដំបូលគ្របរាន ១.៨ ទៅ ២ម
- កម្ពស់រានពីដី ០.៨ ទៅ ១ម
- ទទឹងរានពី ០.៨ ទៅ ១ម
- ប្រើសំណាញ់ពណ៌បៃតង ដើម្បីការពារទឹកភ្លៀង និងពន្លឺថ្ងៃ
- សំណាញ់មុង ធ្វើជញ្ជាំងការពារសត្វល្អិត

* ការធ្វើរោងបណ្តុះកូន អាចធ្វើឱ្យគ្រាប់ដុះល្អ កាត់បន្ថយការរលួយកូន និងការពារកូនដំណាំពីការឆ្លងមេរោគពីពពួកសត្វល្អិតចង្រៃ។

៣. ការបណ្តុះកូន

- ពង្រោយគ្រាប់ពូជក្នុងក្រណាត់ស្បៃជក់ទឹក
- រុំគ្រាប់ពូជឱ្យហប់
- ស្រោចទឹករាល់ថ្ងៃ ឱ្យក្រណាត់សើមល្អ
- ដាក់នៅកន្លែងហប់
- ផ្ចាប់គ្រាប់រយៈពេល ២ ទៅ ៣យប់

- បណ្តុះគ្រាប់ពូជដែលបែកមាត់មុន
- មួយរន្ធ បណ្តុះកូនមួយគ្រាប់
- យកកូនបណ្តុះដាក់លើរានបណ្តុះ រួចគ្របសំណាញ់ការពារសត្វល្អិតពណ៌ស
- ស្រោចទឹកឱ្យគ្រប់គ្រាន់ ពិសេសពេលថ្ងៃត្រង់។ ហាមស្រោចទឹកពេលល្ងាច ព្រោះអាចធ្វើឱ្យគ្រាប់ ឬកូនបន្លែរលួយ
- កូនត្រប់អាយុបាន ១៥ថ្ងៃ ប្រើជី ១៨ ០-៤៦-០ កន្លះស្លាបព្រាបាយ លាយទឹក ១០លីត្រ ស្រោចកូន
- ស្រោចទឹកធម្មតា បន្ទាប់ពីស្រោចជីហើយ។

៤. ការរៀបចំរង

- ទទឹងរង ១ម
- កម្ពស់រងរដូវប្រាំង ២តឹក កម្ពស់រងរដូវវស្សា ៤តឹក
- លាយជីលាមកសត្វពុកផុយ ឬជីកំបុស ៣គ.ក្រ (សម្រាប់ ៣ម²) ជាមួយជី ២០-២០-១៥ (សម្រាប់ ៣ម²)

- ស្រោចទឹកឱ្យជោក
- គ្របចំបើង ឬប្រភេទឆ្លាស្វិចគ្របដី។

៥. ការរៀបចំដាំ

- កាត់បន្ថយការស្រោចទឹកកូនត្រប់ ៥-៧ថ្ងៃ មុនដាំ
- កូនត្រប់អាយុ ២៥-២៨ថ្ងៃ អាចយកទៅដាំបាន
- ដាំកូនត្រប់ពេលល្ងាច
- ពេលព្រឹកស្រោចថ្នាំ ប្រភេទថ្យាមេថូហ្សាម (Thiamethoxam) (*ការពារសត្វល្អិតចង្រៃទ្រីប)
- ដាក់កូនត្រប់ឱ្យត្រូវពន្លឺថ្ងៃ (លើកលែងថ្ងៃត្រង់)
- ១រងដាំ ១ជួរ
- ចន្លោះពីគុម្ពទៅគុម្ពមួយ ប្រវែង ១ម
- ដាំរួច ដោតឈើ កម្ពស់ប្រមាណ ០.៨ម ជួយកូនត្រប់កុំឱ្យដួល មានចន្លោះទទួលពន្លឺ និងខ្យល់ច្រើន ជួយកាត់បន្ថយជំងឺ សត្វល្អិត និងងាយប្រមូលផល
- កាត់ខ្នែងនិងស្លឹកចេញពីគល់ រហូតដល់ខ្នែងផ្កា។

៦. ការដាក់ជី

- រៀងរាល់ ១០ថ្ងៃម្តង
- ឈប់ដាក់ជី ១ខែមុនបញ្ចប់ការប្រមូលផល។

៧. ការកម្ចាត់សត្វល្អិតចង្រៃ

៧.១. ទ្រីប

- វិធានការការពារ
  - ដាំឱ្យរង្វើល
  - សំអាតស្មៅ
  - *ពេលព្រឹកស្រោចថ្នាំ ប្រភេទថ្យាមេថូហ្សាម (Thiamethoxam)
  - កប់ចោលកាកសំណល់ដំណាំបន្ទាប់ពីប្រមូលផល
- វិធានកម្ចាត់
  - បាញ់ថ្នាំថ្យាមេថូហ្សាម ហ្វីប្រូនីល អ៊ីមីដា-ក្លរព្រីដ ឬអាបាមិចទីនលាយទឹកស្អិត បាញ់ឆ្លាស់គ្នា នៅពេលត្រជាក់ (អាចពេលព្រឹក ល្ងាច ឬយប់)។

៧.២. រុយស

- វិធានការការពារ
  - ដាំដោយប្រើគម្របប្លាស្ទិចគ្របដី
  - កម្ចាត់ស្មៅ
  - កប់ចោលកាកសំណល់ដំណាំបន្ទាប់ពីប្រមូលផល
- វិធានកម្ចាត់
  - ដកដើមដែលកើតជំងឺមកពីរុយសកប់ចោល
  - បាញ់ថ្នាំ ថ្យាមេថូហ្សាម អីមីដាក្លរព្រីដ អាបាមិចទីន ដាយណូតធីហ្វ៊ូរ៉ាន់ អេម៉ា-មិចទីន ឬថ្នាំបុយប្រូហ្វេហ្ស៊ីន លាយទឹកស្អិត បាញ់ឆ្លាស់គ្នា នៅពេលត្រជាក់ (អាចពេលព្រឹក ល្ងាច ឬយប់)។

៨. ការប្រមូលផល

- ក្រោយពីដាំបានរយៈពេល ២ខែកន្លះ អាចប្រមូលផលបាន

ព័ត៌មាន និងចំណេះដឹងអំពីបរិស្ថាន កសិកម្ម និងសុខភាព

- គួរប្រមូលផលនៅពេលព្រឹក ឬល្ងាច ដើម្បីរក្សារសជាតិ គុណភាព និងទម្ងន់ផ្លែ។

កំណត់ចំណាំ

ទាញយកឯកសារពី eangsophalleth.com | វេបសាយ | កម្មវិធីទូរស័ព្ទ SOPHALLETH | បណ្តាញសង្គម អ៊ាង សុផល្លែត sophalleth
០៧៦

បច្ចេកទេសដាំត្រសក់ចំណារ

១. ការជ្រើសរើសពូជ

- ពូជល្អ គ្មានជំងឺ
- ពូជត្រសក់មាន ៣ប្រភេទ៖
  - ពូជស្រាល (ត្រសក់បន្លា ឬត្រសក់ជ្រក់)៖
    - អាយុកាលលូតលាស់ខ្លី ប្រមាណពី ៣៥-៤០ ថ្ងៃក្រោយដាំ
    - ផ្លែល្អិតតូចៗ ជាចង្កោមៗ
    - បន្លាច្រើនជួរតាម បណ្តោយនៃផ្លែ
    - ទទឹងផ្លែមិនលើស ១.៥តឹក ប្រវែងជាមធ្យម ០.៨-១តឹក
    - សន្លឹកល្អិត ដើមតូច
    - ផ្កាឈ្មោលច្រើនតាមថ្នាំងនៃដើម
    - រោមក្រាស់លើផ្នែស្លឹក និងដើម
    - គ្រាប់តូចល្អិតស្រួចៗ ហើយខ្លី
    - ទំងន់ ១០០គ្រាប់មានចំនួន ២.៥-៤ក្រាម

- ពូជកណ្តាលៈ
  - អាយុកាលលូតលាស់មធ្យម ប្រមាណពី ៤០-៥០ ថ្ងៃក្រោយដាំ
  - ផ្លែភាគច្រើនពណ៌បៃតងស្រាល ផ្នែកខាងគូទមានពណ៌លឿងខ្ចី
  - ស្លឹកធំស្តើង រាងមូល
  - រោមខ្លីៗ ពណ៌បៃតងធម្មតា
  - ផ្លែច្រើនរាយៗ មិនចង្កោម
  - ទទឹងផ្លែមានប្រវែង០.៣-០.៤តឹក បណ្តោយផ្លែប្រវែងពី ១-១.៣តឹក
  - ផ្លែធំកណ្តាល តូចក្បាល និងកន្ទុយ
  - គ្រាប់សំបែតធំខ្លី
  - ទិន្នផលរាប់ពី ៦-៨តោនក្នុង ១ហ.ត (ភាគច្រើនដាំនៅតាមសួនបន្លែ មិនមានលក្ខណៈទ្រង់ទ្រាយជាផលិតកម្មធំៗឡើយ)

- ពូជធ្ងន់ៈ
  - អាយុកាលលូតលាស់វែង ប្រហែលពី ៥០-៧០ថ្ងៃ ក្រោយដាំ
  - ផ្លែទ្រវែង ពណ៌បៃតងចាស់ ប្រមាណ ២/៣ នៃប្រវែងផ្លែ
  - ថ្នាំងរង្វើលបែកមែកមធ្យម
  - ស្លឹកធំក្រាស់ហើយស្រួច
  - រោមរឹង
  - ទទឹងផ្លែជាមធ្យម ៣.៥ស.ម ប្រវែងជាមធ្យម ១.២-២តឹក
  - គ្រាប់ទ្រវែងស្រួច កំប៉ោងកណ្តាលៗ ទម្ងន់ ១០០គ្រាប់ពី ៣.៥-៥.៥ក្រាម (ច្រើនដាំនៅខេត្តកណ្តាល កំពង់ឆ្នាំង និងកំពង់ចាម)។

- ត្រសក់មិនមែនជាដំណាំប្រកាន់រដូវឡើយ ប៉ុន្តែពូជត្រសក់ក្រោយពីសំរាំងគ្រាប់ហើយ ត្រូវការសម្រាករយៈពេលពី ៤-៦ខែ ទើបអាចដាំដុះបាន។

២. ការជ្រើសរើសរដូវ

- លូតលាស់បានចន្លោះ សីតុណ្ហភាពពី ២០-៣០ អង្សាសេ
- រដូវសមស្របបំផុត គឺនៅចុងរដូវវស្សា ចាប់ពីខែតុលាដល់ខែកុម្ភៈ ព្រោះសីតុណ្ហភាពចុះទាបសំណើមបរិយាកាសខ្ពស់ ភ្លៀងមិនអូសបន្លាយ សីតុណ្ហភាពដីប្រែប្រួលទាប រយៈពេលពន្លឺថ្ងៃមានកម្រិតសមស្រប
- ត្រសក់ជួបកត្តាលំបាកជាច្រើន ចាប់ពីខែមីនាដល់ខែឧសភា គឺសត្វល្អិត ជំងឺបំផ្លាញច្រើនបណ្តាលមកពីលក្ខខណ្ឌអាកាសធាតុមិនសមស្រប ធ្វើឱ្យត្រសក់មានទិន្នផលទាប
- រដូវវស្សា ចាប់ពីខែមិថុនា ដល់ខែកញ្ញា ត្រសក់ច្រើនជួបជំងឺបំផ្លាញច្រើនជាងសត្វល្អិត បណ្តាលមកពីសំណើមដី និងសីតុណ្ហភាពដីប្រែប្រួល។

៣. ការជ្រើសរើសដី

- ដីល្បាប់មាត់ស្ទឹង បឹង ទន្លេ និងដីល្បាយខ្សាច់ មិនដក់ទឹកក្រោយពេលភ្លៀងធ្លាក់ (ទឹកដក់លើសពី ២៤ម៉ោងឡើង ធ្វើឱ្យត្រសក់ងាយកើតជំងឺទំស្លឹក)
- ដីក្រហម និងដីខ្មៅក្នុងតំបន់ខ្ពង់រាប ប៉ុន្តែដីឥដ្ឋ ឬដីជូរត្រសក់លូតលាស់មិនល្អឡើយ
- ដីដែលធ្លាប់ដាំដំណាំប្រភេទអំបូរត្រសក់ច្រើនលើក ត្រូវបន្ថែមជីលាមកសត្វ ២០-៣០តោនក្នុង ១ហ.ត
- pH ៦.៥-៧.៥ (pH ទាបជាង៤ ត្រូវផ្អាកការដាំត្រសក់រយៈពេល ១-២ឆ្នាំ ហើយត្រូវដាំដំណាំអំបូរសណ្តែក ដើម្បីកែលម្អដី)។

៤. ការរៀបចំដី

- ភ្ជួរដីលើកទី១ ហាលចោលច្រើនសប្តាហ៍
- ភ្ជួរ ២-៣លើក មុន លើករងដាំដុះ

- ដាំដោយដោតចំណារបញ្ឈរ៖ ទទឹងរង ប្រវែង ១២តឹក កម្ពស់រង ២.៥-៣តឹក
- ដាំឱ្យវារនៅលើដី៖ទទឹងរងប្រវែងពី ៨-១០តឹក (វិធីនេះត្រសក់ផ្លែតិច ទិន្នផលទាប)

- លក្ខខណ្ឌអាកាសធាតុក្តៅ ត្រូវគ្របដីមុនពេលដាំ ដើម្បីបន្ថយកំដៅដី ស្មៅរក្សាសំណើមបានយូរ និងធ្វើឱ្យដីធូរ មិនហាប់ (ដីហាប់បណ្តាលឱ្យបន្ទុកខ្យល់មិនគ្រប់គ្រាន់ និងប្រវែងឫសខ្លីចាក់បានតិច)។

៥. ការរៀបចំដាំ

- ហាលគ្រាប់ពូជនឹងថ្ងៃក្តៅ រយៈពេល ១-២ ម៉ោង (ដាស់ដំណេកគ្រាប់)
- ត្រាំទឹក រយៈពេល ៤-៥ម៉ោង
- លាងសំអាតគ្រាប់ឱ្យស្អាត ៣-៤លើក មុនពេលផ្ចាប់ត្រាំគ្រាប់ពូជ
- ការផ្ចាប់៖ យកក្រណាត់ជ្រលក់ទឹកឱ្យជោក យកមកខ្ចប់គ្រាប់ពូជនោះ

- កប់ទៅក្នុងដីសើមៗ រយៈពេល១យប់
- មុនដាំ យកគ្រាប់ពូជលាយជាមួយថ្នាំសម្លាប់ផ្សិត ប្រភេទ Captan Zinneb Mancozed កម្រិត ២% ឬលាយថ្នាំកន្លះស្លាបព្រាបាយជាមួយគ្រាប់ពូជ ១គ.ក្រ រួចច្របល់ឱ្យសព្វ
- ដាំដោយដោតចំណារបញ្ឈរ៖
  - ដាំចន្លោះពីគុម្ពមួយទៅគុម្ពមួយ ២.៥តឹក ចន្លោះជួរ ៦តឹក ជម្រៅ ០.២-០.៣តឹក
  - ដាក់ ២-៣គ្រាប់ក្នុងមួយគុម្ព
- ដាំឱ្យវារនៅលើដី៖
  - ចន្លោះជួរ ៨តឹក ចន្លោះគុម្ព ៥តឹក
  - ដាក់ ៣-៤គ្រាប់ក្នុងមួយគុម្ព
- គ្របកំណាត់ចំបើងខ្លីៗពីលើ ឬដីធម្មជាតិពុករលួយ
- ក្រោយដាំភ្លាម ត្រូវពិនិត្យមើលសំណើមដី កាលណាដីស្ងួតខ្លាំង ត្រូវតែស្រោចទឹក

- ក្រោយពីដាំរយៈពេល ៣-៤ថ្ងៃ ក្នុងលក្ខខណ្ឌអាកាសធាតុពេលថ្ងៃ ៣០អង្សា និងពេលយប់ ១៨-២០អង្សា ធ្វើឱ្យត្រសក់លូតលាស់លឿន។

៦. ការស្រោចទឹក

- វគ្គលូតលាស់៖
  - បាញ់ទឹកពីលើល្អជាងការស្រោច ដោយបញ្ចូលតាមចន្លោះជួរ ១ថ្ងៃម្តង ឬ២ដង បរិមាណទឹក ប្រមាណពី ១៤០០ ទៅ ១៦០០ ម^3/ហត
  - ត្រូវការសំណើមដី ជាមធ្យមប្រមាណពី ៥០-៦០ %
- វគ្គបន្តពូជ និងផ្លែ៖
  - អាយុពី ១៥ថ្ងៃឡើង
  - ស្រោចដោយបញ្ចូលតាមចន្លោះរង ១អាទិត្យ ២-៣លើក (គួរកុំបាញ់ទឹកពីលើ ព្រោះធ្វើឱ្យប៉ះពាល់ដល់ការបន្តពូជរបស់ត្រសក់)
  - បរិមាណទឹកសរុបពី ១៨០០-២០០០ម^3/ហត

  - ត្រូវការសំណើមដីពី ៦០-៧០%
  - ត្រូវការទឹកច្រើនជាងគេ រហូតដល់ត្រសក់មានអាយុ ៣០-៤០ថ្ងៃក្រោយដាំ
- វគ្គចេញផ្លែ៖
  - ត្រូវការសំណើមដីទាបមកវិញ ពី ៥០-៦៥%
  - ការបញ្ចូលទឹកលើសពីនេះ ធ្វើឱ្យត្រសក់ចាប់ប្រែពណ៌បៃតងទៅលឿង។

៧. ការថែទាំ

- កម្ចាត់ស្មៅឱ្យស្អាត
- ១០-១៥ថ្ងៃក្រោយដាំ ជ្រំបំបែកដីសើៗ កៀរយកដីពីបាតរងមកលុបគល់ឱ្យជិត

* ចំពោះការដាំដោយគ្របកៅស៊ូខ្មៅ មិនចាំបាច់ជ្រំជ្រោយដីឡើយ

- ការពារចៃកុំឱ្យបំផ្លាញត្រសក់។

៨. ការដោតចំណារ

- ក្រោយជ្រំជ្រោយដី យកមែកឈើក្រៀមៗគ្មានស្លឹក មកដោតបញ្ឈរក្បែរគុម្ពឱ្យញឹក

- ចងឱ្យជាប់។

៩. ការប្រើប្រាស់ជី

- មុនពេលដាំ៖
  - ដាក់ជីធម្មជាតិ ពី ១៥-២០តោន ក្នុង១ហ.ត
  - ជីគីមីប្រភេទ ១៥.១៥.១៥ ចំនួន ១៥០គ.ក្រ
  - ដាក់ទៅក្នុងបាតរណ្តៅ
  - លុបដីឱ្យជិត
- ក្រោយពេលដាំរយៈពេល ១០-១៥ថ្ងៃ៖
  - ជីអាសូតសុទ្ធ (អ៊ុយរ៉េ) ចំនួន ២៥-៣០ គ.ក្រ មកលាយទឹក រួចស្រោចឱ្យចំគុម្ព
  - ស្រោចទឹកធម្មតាម្តងទៀត
- ត្រសក់ចេញផ្កា ១០០% ៖
  - ដាក់ជីគីមីប្រភេទ ១៥.១៥.១៥ ដដែល ចំនួន ១០០គ.ក្រ តាមចន្លោះគុម្ព ហើយលុបដីឱ្យជិត
  - ស្រោចទឹកឱ្យជោក។

១០. ការប្រមូលផល

- ពូជស្រាល៖
  - រយៈពេល ៣៥ទៅ ៤០ថ្ងៃក្រោយដាំ
  - យកកន្ត្រៃកាត់ត្រឹមទងផ្លែ (ហាមប្រឡេះយកតែផ្លែ បណ្តាលឱ្យផ្លែត្រសក់ឆាប់ក្រហមប្រៃពណ៌)
  - ទិន្នផលមធ្យម ចន្លោះពី ៨-១០តោន/១ហ.ត
- ពូជកណ្តាល៖
  - រយៈពេល ៤៥-៥០ថ្ងៃក្រោយដាំ
  - កាត់យកផ្លែ ដូចជាត្រសក់ឯទៀត
  - បេះយកផ្លែស្រស់ មានចំនួនពី ៥-៧លើក
  - ទិន្នផលជាមធ្យម ១០-១២តោន/១ហ.ត ។
- ពូជធ្ងន់៖
  - ប្រមូលផលបានច្រើនលើក ពី ៥-១០ លើក
  - ទិន្នផលជាមធ្យមពី ១០-១៥តោន/១ហ.ត ។

១. ការជ្រើសរើសពូជ

- ពូជល្អ គ្មានជំងឺ
- ពូជត្រសក់ផ្អែមមាន ៣ប្រភេទ៖
  - ពូជសាច់ពណ៌លឿង (សូវិត) នាំចូលពីប្រទេសថៃ
  - ពូជសំបកលឿង សាច់ពណ៌ខៀវ (ពូជស៊ីថង) នាំចូលពីប្រទេសថៃ
  - ពូជសំបកខៀវ សាច់ខៀវ (ពូជតាខាយ) នាំចូលពីប្រទេសចិន

* ត្រសក់ទាំង ៣ពូជនេះ មានការនិយមចូលចិត្តច្រើននៅតាមទីផ្សារ។

២. ការជ្រើសរើសដី

- ដីខ្ពស់មិនលិចទឹកនៅរដូវវស្សា
- រដូវប្រាំង អាចដាំនៅលើដីស្រែ ប៉ុន្តែត្រូវនៅជិតប្រភពទឹក ងាយស្រួលស្រោចស្រព។

៣. ការរៀបចំដី

- ភ្ជួរដីហាលចោល ១សប្តាហ៍
- បាចជីលាមកសត្វពុកផុយ ឬជីកំប៉ុស
- ភ្ជួរបង្កប់ជីទៅក្នុងដី ទុកចោលរយៈពេល ២ថ្ងៃ
- រាស់ឱ្យស្មើ
- កាប់រណ្តៅដាំ ចន្លោះពីរណ្តៅមួយទៅរណ្តៅមួយ ៣តឹក។

៤. ការបណ្តុះកូន

- ជីករណ្តៅ ដាក់ជីកំប៉ុស្ត ឬជីលាមកមាន់ (ទ្រាប់បាត) មួយរណ្តៅ ១ បង្គី
- ចន្លោះពីគុម្ពមួយ ទៅមួយ ៣តឹក
- ពេលដាំរួច ត្រូវស្រោចទឹក
- គ្របកៅស៊ូឆ្លាស្ទិកលើរង (ត្រូវចោះរន្ធតូចៗ ដើម្បីឱ្យមានខ្យល់ចេញចូល)។

៥. ការថែទាំ

- ស្រោចទឹក ១ថ្ងៃ ម្តង

- អាយុពី ២០-៣០ថ្ងៃ ដាក់ជីលាមកមាន់ និងជីកំប៉ុស នៅចន្លោះរង
- ត្រសក់ដុះបាន ៧សន្លឹក ចងទ្រើង ឱ្យត្រសក់វារឡើង
- ត្រសក់ដុះបាន ១៤សន្លឹក
  - បេះខ្នែង ដែលមានក្រោមស្លឹកទី៤ ចោល
  - លើសន្លឹកទី១៤ ត្រូវទុក ខ្នែងតែ ៣ខ្នែង សម្រាប់ទុកយកផ្លែ លើសពីនេះ បេះចោល
  - ខ្នែងទាំងបីនេះមានផ្លែ ៣ តែត្រូវទុកតែមួយផ្លែតែប៉ុណ្ណោះ ដោយជ្រើសរើសផ្លែណាដែលល្អជាងគេ។
- ត្រសក់ច្រើនជួបប្រទះបញ្ហា ដង្កូវចោះស្លឹក និងជំងឺស្លឹកក្រហម។ វិធីផ្សំថ្នាំរុក្ខជាតិ សម្លាប់សត្វចង្រៃ៖
  - ធាតុផ្សំ
    - គ្រាប់ប៊ីកួក ៥ក.ក្រ
    - គ្រាប់ស្លាក់ ៥ក.ក្រ

- គ្រាប់ស្លែង ៥គ.ក្រ
- បណ្តូលពេជ្រ ១០គ.ក្រ ។

▪ វិធីធ្វើប្រើប្រាស់

- ចិញ្ច្រាំធាតុផ្សំខាងលើឱ្យម៉ដ្ត រួចដាក់ក្នុងពាង
- ចាក់ទឹកដាក់ត្រាំ ចំនួន ២៤០លីត្រ
- ទុករយៈពេល ១៥ថ្ងៃ (ទុកក្រោមម្លប់)
- ក្នុងរយៈពេលរក្សាទុក ត្រូវបើកគម្របពាងកូរ ១ថ្ងៃម្តង ដើម្បីឱ្យថ្នាំរាប់កាច់។

▪ វិធីប្រើប្រាស់

- លាយទឹកថ្នាំ ៣លីត្រ ជាមួយទឹកធម្មតា ២០លីត្រ
- ស្រោចទៅលើត្រសក់ នៅពេលល្ងាច (មុនថ្ងៃលិច)។

៦. ការប្រមូលផល

- អាយុ ៦០-៧០ថ្ងៃក្រោយដាំ អាចប្រមូលផលបានហើយ។

១. ការជ្រើសរើសពូជ

- ពូជល្អ គ្មានជំងឺ។

២. ការរៀបចំដី

- ភ្ជួរ ២ ទៅ ៣ដង
- ភ្ជួរលើកទី១ ដើម្បីកំចាត់ស្មៅ។ មុនភ្ជួរ ត្រូវបាញ់ថ្នាំកម្ចាត់ស្មៅ ទុកចោលហាលថ្ងៃរយៈពេល៣ទៅ៧ថ្ងៃ
- ភ្ជួរលើកទី២ រួច រាស់ដីឱ្យរាបស្មើ
- លើករងដាំ កាប់រណ្តៅ ទំហំ៤តឹកបួនជ្រុង ជម្រៅពី ២តឹក-៣តឹក គំលាតគុម្ពមួយទៅមួយ ប្រវែង ១ម។

៣. ការដាំ

- ត្រាំទឹកគ្រាប់ត្រឡាច ៦ទៅ១២ម៉ោង
- ដាក់ដាំក្នុងកន្លោងបណ្តុះកូនសិន។

៤. ការថែទាំ

- ស្រោចទឹក
- ជ្រំគល់ ដកស្មៅ

- ការពារពោគបំផ្លាញ។

៥. ការប្រមូលផល

- រយៈពេល ៣០ ទៅ ៤៥ថ្ងៃ អាចប្រមូលផល។

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ

កំណត់ចំណាំ